ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ស្ពឺ

*******

សំណុំរឿងព្រហ្មទណ្ឌលេខៈ ៨០៣

ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៩

សំណុំរឿងស៊ើបសួរលេខៈ ៥៩០

ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៩

សំណុំរឿងជំនុំជម្រះលេខៈ ៩០

ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០២០

សាលក្រមព្រហ្មទណ្ឌលេខៈ ២៤៥ "ខ"

ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០២០

# ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកំពង់ស្ពឺ

បានបើកសវនាការជាសាធារណៈនៅសាលសវនាការនៃសាលាដំបូងខេត្តកំពង់ស្ពឺ។

–កាលបរិច្ឆេទបើកសវនាការៈ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០២០ វេលារសៀល ។

–កាលបរិច្ឆេទប្រកាសសាលក្រមៈ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០២០ វេលាព្រឹក ។

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា

លោកស្រី [redacted] ចៅក្រម

លោក [redacted] ចៅក្រម

**តំណាងអយ្យការ**

លោក [redacted] ឋានៈព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូង

**ដើម្បីជំនុំជម្រះលើជនជាប់ចោទឈ្មោះ** [redacted] ក្តិប ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរជាងដែក ទីកន្លែងកំណើតនៅ[redacted] ខេត្តកណ្តាល។ ទីលំនៅបច្ចុប្បន្នមុនចាប់ខ្លួនភូមិព្រែកដាច់ ឃុំព្រែកដាច់ ស្រុកលើកដែក ខេត្តកណ្តាល។ឪពុកឈ្មោះ [redacted] ប៊ុនឆន (រ) ម្តាយឈ្មោះ [redacted] ហេង (រ) ប្រពន្ធឈ្មោះ [redacted] ថាន (លែងលះ) មានកូន ០៣នាក់ ជានីតិជនទោសពីមុនគ្មាន។ (ក្នុងឃុំ)

ត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារខេត្តកំពង់ស្ពឺ **តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខៈ** ៦០៤ ចុះថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ ។

ជាប់ៈចោទពីបទៈ **ប៉ុនប៉ងរំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅចំណុចភូមិផ្សារចាស់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩, ២៣៩ នៃក្រមព្រហ្មទណ្ឌ។

**–តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខៈ** ៥៦ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ស្ពឺ។

–ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

**ជនរងគ្រោះ**

-ឈ្មោះ [redacted] ស្រីពេជ្រ ភេទស្រី អាយុ ៣៨ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅបច្ចុប្បន្នភូមិផ្សារចាស់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។

**ឯអង្គហេតុកើតមានឡើងដូចតទៅ:** កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ០៣ និង ៣៨នាទី នៅភូមិផ្សារចាស់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ មានករណីប៉ុនប៉ងរំលោភសេពសន្ថវៈមួយបានកើតឡើងៈដលបង្កដោយជនសង្ស័យឈ្មោះ [redacted] ក្តិប ដោយឈ្មោះ [redacted] ក្តិប បានផ្លោះរបង

ចូលទៅក្នុងបរិវេនផ្ទះទៅលើជនរងគ្រោះឈ្មោះ [redacted] ស្រីពេជ្រ ក្នុងគោលបំណងរំលោភសេពសន្ថវៈទៅលើឈ្មោះ [redacted] ស្រីពេជ្រ តែត្រូវបានឈ្មោះ [redacted] ស្រីពេជ្រ ប្តឹងសមត្ថកិច្ចតែម្តង។

## នាពេលសវនាការ

**ក្រោយពីបានៈ**

- ស្តាប់ និងសួរចម្លើយជនជាប់ចោទឈ្មោះ [redacted] ក្លិប
- ស្តាប់ អំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] ស្រីពេជ្រ
- ស្តាប់ អំណានចម្លើយសាក្សីឈ្មោះ [redacted] សុវណ្ណារ៉ា
- ស្តាប់ក្រឡាបញ្ជីអានរបាយការណ៍ និងកំណត់ហេតុផ្សេងៗទៀត
- ស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
- ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
- ស្តាប់ជនជាប់ចោទសំណូមពរផ្សេងៗ
- ក្រោយពីបានពិនិត្យភស្តុតាង និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១.តាមរបាយការណ៍ស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ចម្លើយជនរងគ្រោះឈ្មោះ [redacted] ស្រីពេជ្រ ចម្លើយសាក្សីឈ្មោះ [redacted] សុវណ្ណារ៉ា មានភាពស៊ីសង្វាក់គ្នាអាចបញ្ជាក់បានថាជនជាប់ចោទឈ្មោះ [redacted] ក្លិប ពិតជាបានធ្វើសកម្មភាពផ្លោះរបងចូលទៅក្នុងបរិវេនផ្ទះរបស់ជនរងគ្រោះ កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ ស្ថិតនៅភូមិផ្សារចាស់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។

តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ក្លិប បានឆ្លើយថា: បានចូលមកក្នុងហាងសម្រស់កំពង់ស្ពឺ បានចំនួនបីលើក លើកទី០១ បានជិះម៉ូតូម៉ាក XR មកអង្គុយលេងក្នុងកញ្ចុះបានចាប់ចិត្តនារីម្នាក់ និងនៅថ្ងៃកើតហេតុបានជិះម៉ូតូម៉ាក XR ខាងលើមកឈប់មុខហាងដោយទ្វាររបងចាក់សោរពេលនោះបានទុកម៉ូតូក្រៅរបង ហើយផ្លោះរបងចូលទៅក្នុងហាងទៅគោះទ្វារបន្ទប់ស្រីម្នាក់ដែលលួចស្រឡាញ់ តែពេលកំពុងគោះទ្វារស្រីម្នាក់នោះស្រែកសួរថានរណាគេ និងថែមទាំងជេរ ហើយតបវិញថា អូនឯងចេះជេរមកពីណ៉ាពិរោះម្លេះ មកនេះគឺមកស្រលាញ់អូនឯង ។

តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីពេជ្រ បានឆ្លើយថា: ជនជាប់ចោទឈ្មោះ [redacted] ក្លិប បានមកអាហារដ្ឋានចំនួន ០៣ លើក ។នៅយប់កើតហេតុបានដេកនៅក្នុងបន្ទប់ស្រាប់តែឮសំលេងបើកសោរបន្ទប់ លុះបើកមិនបានក៏គោះទ្វារបន្ទប់ខ្លាំងៗ ហើយស្រែកថាឲ្យបើកទ្វារបន្ទប់ និងជាជាងធ្វើសោរ ហើយខ្លួនក៏ស្រែកជេរពីក្នុងបន្ទប់ថាជាងសោរម៉ែហែងអីមកធ្វើសោរទាំងស្មើនេះ រួចមកជនជាប់ចោទឈ្មោះ [redacted] ក្លិប បានឆ្លើយថា អូនឯងអ្នកណាបង្រៀនឲ្យអូនឯងជេរពិរោះម្លេះ ។ខ្លួនក៏គោះជញ្ជាំងបន្ទប់ដាស់ម្តាយ ហើយម្តាយក៏ភ្ញាក់ក៏យកដំបងដេញវាយឲ្យចេញ តែឈ្មោះ [redacted] ក្លិប មិនព្រមចេញក៏បានទូរស័ព្ទរាយការណ៍ទៅសមត្ថកិច្ចមកចាប់ខ្លួនតែម្តង។

តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] សុវណ្ណារ៉ា បានឆ្លើយថា:នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ កំពុងដេកលក់ក្នុងបន្ទប់ឮសំឡេងគោះទ្វារ ហើយឮសំឡេងម្ចាស់ហាងស្រែកសួរនរណាមករកអី ក៏ឮសំឡេងមនុស្សប្រុសឆ្លើយតបវិញថា មកធ្វើសោរ បន្ទាប់មកមីងចុងភៅឈ្មោះ ហ៊ាង ស្រែកហៅឲ្យទៅមើល ,និងបានចាប់ទាញឈ្មោះ [redacted] ក្លិប នេះចេញពីមុខបន្ទប់ម្ចាស់ហាងឈ្មោះ [redacted] ស្រីពេជ្រ តែឈ្មោះ [redacted] ក្លិប នៅតែរើបំរាស់ស្ទុះទៅគោះទ្វារ និងបានសួរថា បងមករកអីស្មើនេះ និងឆ្លើយតបថាមករកមនុស្ស ។

អំពើខាងលើនេះជាបទល្មើសរំលោភលំនៅឋាន ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រ ២៥៩ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

. ការចោទប្រកាន់ពីបទប៉ុនប៉ងរំលោភសេពសន្ថវៈ តុលាការយល់ឃើញថាពុំមានធាតុផ្សំបទល្មើសគ្រប់គ្រាន់នៅឡើយ ដោយកាលៈទេសៈ និងស្ថានភាពពេលកើតហេតុក៏ដូចជាអំពើប្រព្រឹត្តរបស់ជនជាប់ចោទ តាមចម្លើយជនរងគ្រោះ គឺបង្ហាញឲ្យឃើញត្រឹមជនជាប់ចោទបានផ្លោះរបងចូលក្នុងបរិវេនក្នុងផ្ទះជនរងគ្រោះប៉ុណ្ណោះ។

**២.មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ** [redacted] ក្លិប ពីបទ: **រំលោភលំនៅឋាន**។ប្រព្រឹត្តនៅចំណុចភូមិផ្សារចាស់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៩ នៃក្រមព្រហ្មទណ្ឌ។

**៣.វត្ថុចាប់យកមាន:** ម៉ូតូមួយគ្រឿង ម៉ាក XR ពណ៌ខ្មៅ ពាក់ផ្លាកលេខ កណ្តាល 1Y-0412។គប្បីសម្រេចប្រគល់ឲ្យម្ចាស់ដើមវិញ។

៤.ឈ្មោះ [redacted] ស្រីពេជ្រ មិនបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទាមទារសំណងនិងបានដកពាក្យបណ្តឹងទៀតទេ។តុលាការពុំមានសមត្ថកិច្ចពិនិត្យសម្រេចបន្ថែមទៀតទេ។

៥.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ: ក្រោយពីបានបញ្ចប់ការសួរដេញដោលនាពេលសវនាការ ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ឃើញថាជនជាប់ចោទឈ្មោះ [redacted] ក្លិប បានឆ្លើយថាខ្លួនបានទៅផ្លោះរបងផ្ទះជនរងគ្រោះ ហើយឈានទៅដល់ការគោះទ្វារដើម្បីព្យាយាមសម្រេចចំណង់រួមភេទក្រោយខណៈខ្លួនស្ថិតនៅក្នុងភាពស្រវឹង ដែលធ្វើឲ្យខ្លួនមានចំណង់ដោយសារកាលៈទេសៈនៃការរារាំងដោយជនរងគ្រោះបានស្រែក និងក្រុមគ្រួសាររបស់ជនរងគ្រោះមកអន្តរាគមន៍ទាន់ធ្វើឲ្យគោលបំណងដែលខ្លួនចង់បំពេញសកម្មភាពរំលោភបំពានលើរាងកាយស្ត្រីនោះ ត្រូវបានអាក់ខានវិញ។ ហេតុនេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ក្លិប តាមដីកាសន្និដ្ឋានស្ថាពរលេខ: **៨០៩ អ.យ/១៩** ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ ទុកជាបានការដដែល និងសុំឲ្យតុលាការពិនិត្យសម្រេចតាមច្បាប់។

៦.មេធាវីការពារសិទ្ធិជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាន: អង្គហេតុកាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ ជនជាប់ចោទឈ្មោះ [redacted] ក្លិប ដោយស្ថិតក្នុងស្ថានភាពស្រវឹង ហើយបានបាត់បង់ម្ចាស់ការលើខ្លួនឯងក៏បានផ្លោះរបងមកគោះទ្វារបន្ទប់របស់ម្ចាស់ហាងឈ្មោះ [redacted] ស្រីពេជ្រ និងបានស្រែកឡូឡាពេញនោះដែរទៀតផង ម្យ៉ាងវិញទៀតថាជនជាប់ចោទនិយាយស្តាប់គ្នាមិនបាន ទើបធ្វើឲ្យឈ្មោះ [redacted] ស្រីពេជ្រ ដែលជាម្ចាស់ហាងនោះទាក់ទងទៅសមត្ថកិច្ចឲ្យនាំខ្លួនជនជាប់ចោទទៅកាន់បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តកំពង់ស្ពឺតែម្តង កាលដែលតុលាការធ្វើការចោទប្រកាន់ និងឃុំខ្លួនជនជាប់ចោទអស់រយៈពេលយ៉ាងយូរនេះ គឺពិតជាបានធ្វើឲ្យប៉ះពាល់ដល់ជនជាប់ចោទខ្លាំងទាំងផ្លូវកាយ និងផ្លូវចិត្ត ព្រមទាំងធ្វើឲ្យជនជាប់ចោទទទួលរងនូវភាពអយុត្តិធម៌ជាខ្លាំងផងដែរ ដោយមូលហេតុថាទង្វើរបស់ជនជាប់ចោទបានប្រព្រឹត្តនោះពុំមែនជាបទល្មើសប៉ុនប៉ងរំលោភសេពសន្ថវៈនោះឡើយ ពីព្រោះពុំមានសញ្ញាណជាក់លាក់ច្បាស់លាស់ណាមួយបង្ហាញថា ជនជាប់ចោទមានឆន្ទៈក្នុងការចូលទៅរំលោភដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ដែលឆ្លុះបញ្ចាំងការខ្វះនូវធាតុផ្សំនៃបទល្មើស យោងទៅតាមការជជែកសួរដេញដោល និងយោងទៅតាមអង្គហេតុបានបង្ហាញឲ្យឃើញច្បាស់ថាជនជាប់ចោទគ្រាន់តែបានធ្វើការផ្លោះរបងចូលទៅក្នុងបរិវេនផ្ទះដើមបណ្តឹងរដ្ឋប្បវេណី និងបានដើរគោះទ្វារគ្រប់បន្ទប់ទាំងអស់ និងបានស្រែកឡូឡាផ្អើលគេផ្អើលឯង ផ្ទុយពីចេតនាប៉ុនប៉ងរំលោភសេពសន្ថវៈពិតប្រាកដ ដោយធ្វើការផ្លោះរបងដោយស្ងៀមស្ងាត់ប្រុងប្រយ័ត្នខ្លាចគេដឹងខ្លាចគេឮ បន្ទាប់មកក្រោយពីពេលនោះឡូវគួរតែរត់គេចខ្លួន តែជនជាប់ចោទនៅឈរទីនោះមិនបានរត់គេចទៅណានោះទេ ហើយក៏បានស្រែកឡូឡាដែរមុនពេលធ្វើការគោះទ្វារ ដោយសារឥទ្ធិពលនៃគ្រឿងស្រវឹង ទើបជាមូលហេតុធ្វើឲ្យជនជាប់ចោទប្រព្រឹត្តអំពើចូលក្នុងបរិវេនផ្ទះរបស់អ្នកដទៃ។ប៉ុន្តែក្នុងនេះផងដែរសូមធ្វើការទាញចំណាប់អារម្មណ៍អង្គសវនាការទាំងមូលមេត្តាជ្រាប កាន់តែច្បាស់ផងដែរថាដោយសារតែកត្តាគ្រួសារ ផ្លូវចិត្ត ការបែកបាក់គ្រួសារប្រពន្ធផិតក្បត់ ទ្រព្យសម្បត្តិដែលខំរកទាំងអស់ត្រូវបានប្រពន្ធ

បំផ្លិចបំផ្លាញទាំងអស់គ្មានសល់ ព្រមទាំងនៅថ្ងៃនោះផងដែរបានសេពគ្រឿងស្រវឹងអស់ច្រើន ទើបធ្វើឲ្យជនជាប់ចោទទៅប្រព្រឹត្តអំពើចូលផ្ទះអ្នកដទៃទាំងដែលខ្លួនមិនមានស្មារតីក្នុងការគ្រប់គ្រង ម្យ៉ាងវិញទៀត ពាក្យសុំដកពាក្យបណ្តឹង របស់ដើមបណ្តឹងរដ្ឋប្បវេណីក៏បានបញ្ជាក់ត្រង់ចំណុចមួយបញ្ជាក់ច្បាស់លាស់ថា ជនជាប់ចោទបានធ្វើការផ្លោះរបងចូលក្នុងបរិវេនផ្ទះរបស់គាត់ ហើយគោះទ្វារបន្ទប់ទាំងអស់ និងបានស្រែកឡូឡាពេញទីនោះ ដោយសារតែស្រវឹងនិយាយស្តាប់គ្នាពុំបាននេះហើយ ដែលជាមូលហេតុធ្វើឲ្យគាត់ប្តឹងទៅមន្ត្រីកងរាជអាវុធហត្ថឲ្យធ្វើការនាំខ្លួនកូនក្តីរបស់ខ្លួន មកកាន់បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តកំពង់ស្ពឺតែម្តង ចំណុចមួយទៀតដែលខ្លួនចង់លើកឡើងពីឈ្មោះ [redacted] ស្រីពេជ្រ និងឈ្មោះ ស្រីពេជ្រ យោងតាមការជជែកសួរដេញដោលខាងលើឃើញថាឈ្មោះ ស្រីពេជ្រ ដែលជនជាប់ចោទបាននិយាយនោះ មិនមែនជាឈ្មោះ [redacted] ស្រីពេជ្រ ដែលមានអាយុ ៣៩ឆ្នាំនោះទេ គឺជាបុគ្គលពីរនាក់ផ្សេងគ្នា ដូច្នេះសូមសំណូមពរដោយហេតុថាជនជាប់ចោទមានម្តាយឪពុកត្រូវចិញ្ចឹមតែរក្សាជាចាំបាច់បំផុត និងមានកូនក្នុងបន្ទុកដែលត្រូវរកស៊ីចិញ្ចឹម ម្យ៉ាងវិញទៀតខាងដើមបណ្តឹងរដ្ឋប្បវេណីក៏បានដកពាក្យបណ្តឹង ឈប់ប្តឹងហើយដោយសារកត្តានៃការខ្វះធាតុផ្សំអត្តនោម័តទាក់ទងនឹងបទល្មើស ប៉ុនប៉ងរំលោភសេពសន្ថវៈដូច្នេះ សំណូមពរតុលាការមេត្តាលើកលែងឲ្យជនជាប់ចោទរួចខ្លួនពីបទចោទ និងដោះលែងឲ្យមានសេរីភាពឡើងវិញ។

## ហេតុដូច្នេះសម្រេច

១.ផ្តន្ទាទោសឈ្មោះ [redacted] ក្តិប ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរជាងដែក ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល។ទីលំនៅបច្ចុប្បន្នមុនចាប់ខ្លួនភូមិព្រែកដាច់ ឃុំព្រែកដាច់ ស្រុកលើកដែក ខេត្តកណ្តាល។ឪពុកឈ្មោះ [redacted] ប៊ុនឆន (រ) ម្តាយឈ្មោះ [redacted] ហេង (រ) ប្រពន្ធឈ្មោះ [redacted] ថាន (លែងលះ) មានកូន ០៣នាក់ ជានីតិជន ទោសពីមុនគ្មាន។ (ក្នុងឃុំ)

ដាក់ពន្ធនាគារចំនួន: ០៧ (ប្រាំពីរ) ខែ។

ជាប់ចោទពីបទ: **រំលោភលំនៅឋាន** ប្រព្រឹត្តនៅចំណុចភូមិផ្សារចាស់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៩ នៃក្រមព្រហ្មទណ្ឌ។

២.ប្រគល់ម៉ូតូ មួយគ្រឿង ម៉ាក XR ពណ៌ខ្មៅ ពាក់ផ្លាកលេខ កណ្តាល 1Y-0412 ឲ្យទៅឈ្មោះ [redacted] ក្តិប។

៣.សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ក្តិប ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រម** **ចៅក្រម** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]